# ការចំរើនលូតលាស់របស់ពួកគេនៅសម័យថ្មីនេះ




<<ប៉មយាម>>
កើនពី៦.០០០ក្បាល
ជាភាសាតែមួយប៉ុណ្ណោះ
រហូតដល់ជាង១៣២ភាសា

**ប្រវត្តិ**សាស្ត្រសម័យថ្មីរបស់ស្មរបន្ទាល់ព្រះយេហូវ៉ា បានចាប់ផ្តើមជាងមួយរយឆ្នាំមុននេះ។ នៅដើមនៃទសវត្ស១៨៧០ ពួកអ្នកសិក្សាព្រះគម្ពីរដែលមិនលេចធ្លោមួយក្រុមបានចាប់ផ្តើមនៅទីក្រុងអាលីគេនីរដ្ឋប៉ិនស៊ីវ៉ានី សហរដ្ឋអាមេរិក ដែលទីក្រុងនោះឥឡូវនេះរួមជាចំណែកនៃទីក្រុងផិតបឺក។ ឆាល្ស ថេស្ស រ៉ាសិល ជាអ្នកដឹកនាំនៃក្រុមនោះ។ នៅខែកក្កដាឆ្នាំ១៨៧៩ ទស្សនាវដ្ដី *ប៉មយាម នៃភ្នំស៊ីយ៉ូនដែលប្រកាសវត្តមានរបស់ព្រះគ្រីស្ទ* លេខទីមួយបានចេញមក។ នៅឆ្នាំ១៨៨០ មានក្រុមជំនុំជាច្រើនដែលបានលូតលាស់ឡើងពីក្រុមសិក្សាព្រះគម្ពីរតូចតែមួយនោះទៅដល់រដ្ឋជិតខាងគេជាច្រើន។ នៅឆ្នាំ១៨៨១ សមាគមប៉មយាមខាងខិត្តប័ណ្ណនៃភ្នំស៊ីយ៉ូនបានត្រូវបង្កើតឡើង ហើយនៅឆ្នាំ១៨៨៤ សមាគមនេះបានត្រូវរួបរួមគ្នាជាសាជីវកម្ម ដោយមានលោករ៉ាសិលជាប្រធាន។ ក្រោយមកឈ្មោះសមាគមបានត្រូវផ្លាស់ប្តូរទៅជាសមាគមប៉មយាមខាងព្រះគម្ពីរនិងខិត្តប័ណ្ណ។ មនុស្សជាច្រើនបានទៅធ្វើបន្ទាល់ពីផ្ទះមួយទៅផ្ទះមួយ ដោយប្រគល់ប្រកាសនវត្ថុខាងព្រះគម្ពីរ។ ពួកអ្នកដែលធ្វើការផ្សាយពេញពេលនេះនៅឆ្នាំ១៨៨៨មានចំនួន៥០នាក់។ ក៏ប៉ុន្តែ ឥឡូវអ្នកផ្សាយពេញពេលមានចំនួនមធ្យមជាង៧០០.០០០នាក់ទូទាំងពិភពលោក។

នៅឆ្នាំ១៩០៩ កិច្ចការនេះបានចម្រើនទៅជាកិច្ចការអន្តរជាតិ ហើយមន្ទីរចាត់ការរបស់សមាគមប៉មយាមបានត្រូវផ្លាស់កន្លែងទៅទីក្រុងប្រ៊ុគ្លីន រដ្ឋញូយ៉ក ហើយសព្វថ្ងៃនេះនៅមានអាស័យដ្ឋានដដែល។ ធម្មទានបានត្រូវបោះពុម្ពនៅសារពត៌មាននៅសហរដ្ឋអាមេរិក ប្រទេសកាណាដា ហើយទ្វីបអឺរ៉ុប។ គេបានចែកចាយសៀវភៅ សៀវភៅស្តើង ហើយខិត្តប័ណ្ណរាប់រយលានក្បាល។

នៅឆ្នាំ១៩១២ គេចាប់ផ្តើមធ្វើល្ខោនរូបភាពនៃការបង្កើត។ ដោយរូបថតបញ្ចាំងហើយភាពយន្តដែលមានសម្លេងរឿងល្ខោននេះ បានសម្តែងពីដំណើររឿងនៃការបង្កើតផែនដីរហូតដល់ទីបញ្ចប់មួយពាន់ឆ្នាំនៃការគ្រងរាជ្យរបស់ព្រះគ្រីស្ទ។ នៅឆ្នាំ១៩១៤ ល្ខោននេះបានបង្កើតមុនគេបង្អស់ចំពោះភាពយន្តដែលមានសម្លេង។

# ឆ្នាំ១៩១៤

ពេលវេលាដ៏សំខាន់ជិតមកដល់ហើយ ។ នៅឆ្នាំ១៨៧៦អ្នកសិក្សាព្រះគម្ពីរ ឈ្មោះឆាល្សថេស្សរ៉ាសិលបានសរសេរអត្ថបទមួយដែលមានចំណងជើងថា «គ្រារបស់សាសន៍ដទៃ តើពេលណាត្រូវចប់?» ហើយប្រគល់ដល់ទស្សនាវដ្ដី *ការពិនិត្យព្រះគម្ពីរ* ដែលបោះពុម្ពផ្សាយចេញពីទីក្រុងប្រ៊ុគ្លីនរដ្ឋញូយ៉ក ដែលនៅអត្ថបទនោះក្នុងទំព័រទី២៧ ខែតុលាចែងថា:

«ទាំងប្រាំពីរខួបរបស់គ្រានៃសាសន៍ដទៃនឹងត្រូវចប់នៅឆ្នាំ១៩១៤គ.ស.» ។

គ្រារបស់សាសន៍ដទៃជាពេលវេលាដែលព្រះយេស៊ូបានមានបន្ទូលថាជា «គ្រាកំណត់របស់សាសន៍ដទៃ» ។ (លូកា ២១:២៤ *ព.ថ.*) គ្រប់ការទាំងអស់ដែលគេទន្ទឹងចាំឱ្យកើតមានឡើងនៅឆ្នាំ១៩១៤នោះ មិនកើតឡើងទេ ប៉ុន្តែឆ្នាំនោះពិតជាបានសំគាល់ទីបញ្ចប់នៃគ្រារបស់សាសន៍ដទៃ និងជាឆ្នាំដែលមានសេចក្ដីសំខាន់យ៉ាងពិសេស ។ អ្នកប្រវត្តិសាស្ត្រនិងអ្នកធ្វើអត្ថាធិប្បាយជាច្រើនយល់ស្របថាឆ្នាំ ១៩១៤ជាចំណុចពេលវេលានៃការផ្លាស់ប្ដូរយ៉ាងធំក្នុងប្រវត្តិសាស្ត្រមនុស្សលោក ។ សេចក្ដីដកស្រង់ដែលមានបន្តបន្ទាប់មកនេះ បង្ហាញយ៉ាងជាក់ស្ដែងអំពីរឿងនេះ:

**ពេលដែលមានការផ្លាស់ប្ដូរសំខាន់មួយ**
**ក្នុងប្រវត្តិសាស្ត្រមនុស្សលោក**



«ឆ្នាំក្រោយបង្អស់ដែលមានភាពធម្មតាក្នុងប្រវត្តិសាស្ត្រគឺ១៩១៣ ដែលជាឆ្នាំមុនចាប់កំណើតនៃសង្គ្រាមលោកលើកទី១» ។ វិចារណកថាមួយក្នុងសារពត៌មានថៃម្ស-ហេរ៉ាល្ដ វ៉ាស៊ីនតោនស.រ.អ. ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៤៩ ។

«កំឡុងពេល៧៥ឆ្នាំពីឆ្នាំ១៩៨៩ ដែលមានសង្គ្រាមលោកទាំងពីរលើកនិងសង្គ្រាមត្រជាក់ នោះពួកអ្នកប្រវត្តិសាស្ត្រីតតែឃើញថាជាសម័យតែមួយគត់ដែលដាច់ពីគេ ជាគ្រាដែលប្រទេសជាច្រើនចូលច្បាំងក្នុងសង្គ្រាម ងើបពីសង្គ្រាម ឬប្រុងប្រៀបចូលធ្វើសង្គ្រាម» ។ ទស្សនាវដ្ដីញូយ៉កថៃម្ស ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៥ ។

«លោកីយ៍ទាំងមូលពិតជាបានផ្ទុះក្នុងសង្គ្រាមលោកលើកទី១ ហើយយើងនៅតែមិនទាន់យល់ហេតុអ្វីនោះទេ ។ មុនពេលនោះ មនុស្សលោកបានគិតស្មានថា ផែនដីជាទីបរមសុខពិតជាអាចទទួលបាន ។ នៅពេលនោះគឺមានសន្តិសុខនិងភាពចម្រើន ។ បន្ទាប់មកគ្រប់ទាំងអស់បានផ្ទុះឡើង ។ តាំងពីពេលនោះមក មនុស្សយើងដូចជាមានជីវិតដែលគ្មានសកម្មភាពឡើយ . . . មនុស្សជាច្រើននាក់បានត្រូវស្លាប់ក្នុងសតវត្សនេះ ជាងអស់អ្នកដែលបានត្រូវស្លាប់ក្នុងគ្រប់ប្រវត្តិសាស្ត្រទាំងអស់» ។ វិជ្ជាបណ្ឌិត វ៉លកឺ-ភើស៊ី ទស្សនាវដ្ដីដំណឹងខាងវិជ្ជាពេទ្យអាមេរិកកាំង ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។

ជាង៥០ឆ្នាំក្រោយពីឆ្នាំ១៩១៤ រដ្ឋបុរសអាល្លឺម៉ង់ម្នាក់ឈ្មោះ កុនរ៉ាដ អាដិនអោ បានសរសេរថាៈ «សន្តិសុខហើយភាពស្ងប់ស្ងៀមបានត្រូវបាត់បង់ចេញពីជីវិតមនុស្ស តាំងពីឆ្នាំ១៩១៤មក» ។ *ទស្សនាវដ្ដីពេរីតេរីទិសខាងលិច* ទីក្រុងគ្លីវឡាន្ត រដ្ឋអូហៃយ៉ូ ស.រ.អ. ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៦។

ប្រធានទីមួយនៃសមាគមប៉មយាម

លោករ៉ាសិលបានទទួលមរណភាពនៅឆ្នាំ១៩១៦ហើយឆ្នាំក្រោយបានត្រូវស្នងដោយលោកយ៉ូសេប រ៉ូធើហ្វឺត។

ការផ្លាស់ប្ដូរជាច្រើនបានកើតមានឡើងនៅពេលនោះ។

គេបានបញ្ចេញជាលើកដំបូងនូវទស្សនាវដ្ដីមួយដែលឈ្មោះទស្សនាវដ្ដី *សម័យភោគផល* ជាគូនៃទស្សនាវដ្ដីប៉មយាម (សព្វថ្ងៃមានឈ្មោះទស្សនាវដ្ដី*ភ្ញាក់រឭក!* ហើយចំនួនដែលចេញរៀងរាល់ដង ពិរដងរៀងរាល់ខែ) ជាង២០.០០០.០០០ក្បាល និងជាង៨០ភាសា។

ការធ្វើបន្ទាល់ពីផ្ទះមួយទៅផ្ទះមួយបានត្រូវចាត់ទុកថាជាការសំខាន់ជាងពីមុនទៅទៀត។

ដើម្បីសម្ដែងថាពួកគេខុសប្លែកពីពួកសាសនានិកាយជាច្រើនរបស់ពិភពគ្រីស្ទាន ពួកគ្រីស្ទានទាំងនេះបានទទួលយកដោយអំណរនូវឈ្មោះស្មរបន្ទាល់ព្រះយេហូវ៉ានៅឆ្នាំ១៩៣១។

ឈ្មោះនេះមានមូលដ្ឋានក្នុងព្រះគម្ពីរ អេសាយ ៤៣:១០-១២។

ពួកគេបានប្រើវិទ្យុយ៉ាងសុសសាយក្នុងទសវត្ស១៩២០ ព្រមទាំង១៩៣០។ នៅឆ្នាំ១៩៣៣ សមាគមប៉មយាមកំពុងប្រើ៤០៣ស្ថានីយវិទ្យុ ដើម្បីផ្សាយការបង្រៀនអំពីព្រះគម្ពីរ។ បន្ទាប់មក គេបានឈប់ប្រើវិទ្យុ តែប្រើការផ្សាយតាមផ្ទះជំនួសវិញ។ ពួកស្មរបន្ទាល់បានប្រើសុន្ទរកថាដែលបានថតហើយ យកមកចាក់លើថាសសម្លេង ដើម្បីជួយអស់អ្នកដែលចាប់អារម្មណ៍នោះ។

## ជ័យជំនះខាងតុលាការ

**ការបំរើដែលមានសារៈសំខាន់ ចំពោះសេរីភាពពលរដ្ឋ**

ក្នុងកំឡុងពេលទសវត្ស១៩៣០ហើយ១៩៤០ គឺមានការចាប់ឃុំឃាំងជាច្រើននៃពួកស្មរបន្ទាល់ដែលធ្វើកិច្ចបំរើនេះ ហើយគេបានតស៊ូនឹងប្ដឹងនៅតុលាការ ដើម្បីឱ្យបានរក្សាទុកសេរីភាពខាងពាក្យសំដី ខាងពតិមាន ខាងរួមប្រជុំគ្នា ហើយខាងការថ្វាយបង្គំ។

នៅក្នុងសហរដ្ឋអាមេរិក ការសុំឱ្យតុលាការជាន់ខ្ពស់នៃសហរដ្ឋអាមេរិកពិនិត្យឡើងវិញនូវចំណាត់ការពីតុលាការជាន់ទាបនោះជាលទ្ធផល ស្មរបន្ទាល់ព្រះយេហូវ៉ាបានឈ្នះ៤៣បណ្ដឹងក្ដី។ ស្រដៀងនឹងគ្នានោះ ការវិនិច្ឆ័យល្អបានត្រូវទទួលពីតុលាការជាន់ខ្ពស់នៅប្រទេសជាច្រើន។

សាស្ត្រាចារ្យលោកប្រេដិន បានសរសេរក្នុងសៀវភៅរបស់លោកដែលមានឈ្មោះថា *ពួកនេះជាអ្នកជឿដែរ* អំពីការឈ្នះខាងតុលាការទាំងនេះនៃស្មរបន្ទាល់ព្រះយេហូវ៉ាថា :

«ពួកនេះបានធ្វើការបំរើដែលមានសារៈសំខាន់ចំពោះ? ប្រជាធិបតេយ្យភាព ដោយសារការតស៊ូរបស់គេឱ្យរក្សាសិទ្ធិពលរដ្ឋរបស់គេ ព្រោះដោយការតស៊ូរបស់គេនោះ ពួកគេបានជួយគ្រប់ទាំងក្រុមមនុស្សភាគតិចក្នុងសហរដ្ឋអាមេរិកឱ្យបានទទួលសិទ្ធិទាំងនោះដែរ» ។

# កម្មវិធីអប់រំដ៏ពិសេស

លោកយ៉ូសេបរ៉ូធើហ្វឺតបានទទួលមរណភាពនៅឆ្នាំ១៩៤២ ហើយលោកណេថិន ន័របានទទួលតំណែងជាប្រធាន។ កម្មវិធីអប់រំរួបរួមគ្នាមួយបានត្រូវចាប់ផ្ដើមឡើង។ នៅឆ្នាំ១៩៤៣ គេបានតាំងឡើងនូវសាលាអប់រំមួយពិសេសសម្រាប់សាសនទូត ហៅថាសាលាអប់រំគីលាតខាងព្រះគម្ពីរនៃសមាគមប៉មយាម។ តាំងពីពេលនោះមក អ្នកចប់ការសិក្សាពីសាលានេះបានត្រូវចាត់ឱ្យទៅប្រទេសនានាជុំវិញផែនដី។ ក្រុមជំនុំថ្មីៗក៏បានលេចមានឡើងនៅក្នុងប្រទេសដែលមិនមានពីមុននោះ ហើយការិយាល័យសាខាដែលបានតាំងឡើងតាមអន្តរជាតិគឺមានជាង១០០។ យូរៗម្ដងសាលាអប់រំពិសេសបានត្រូវតាំងឡើងសម្រាប់អប់រំអ្នកចាស់ទុំក្នុងក្រុមជំនុំ អ្នកធ្វើការដោយស្ម័គ្រចិត្តតាមការិយាល័យសាខា ហើយអស់អ្នកដែលធ្វើពេញពេល (ជាអ្នកត្រួសត្រាយ) នូវកិច្ចបំរើនៃការធ្វើបន្ទាល់។ ហើយក៏មានសាលាបែបពិសេសមួយចំនួនសំរាប់អ្នកបំរើ ដែលមានដំណើរការនៅឯមណ្ឌលអប់រំនៅឯក្រុងផាតឺសិន រដ្ឋញូយ៉ក។



លោក ណេថិនន័រ បានទទួលមរណភាពនៅឆ្នាំ១៩៧៧។ សេចក្ដីផ្លាស់ប្ដូរក្រោយបង្អស់មួយក្នុងអង្គការ ដែលលោកមានចំណែកក្នុងការសម្រេចមុននឹងលោកស្លាប់នោះ គឺជាការពង្រីកឡើងនូវគណៈអភិបាលក្នុងមន្ទីរចាត់ការនៅទីក្រុងប្រ៊ុគ្លីន។ នៅឆ្នាំ១៩៧៦ ភារៈខាងការចាត់ការបានត្រូវបែងចែកហើយចាត់ទៅដល់គណៈផ្សេងៗ ដែលធ្វើឡើងពីសមាជិកនៃគណៈអភិបាលដែលម្នាក់ៗបានដកពិសោធជាច្រើនទសវត្សមកហើយជាអ្នកបំរើព្រះ។

# រោងចក្របោះពុម្ពពង្រីកឡើង




ប្រវត្តិសាស្ត្ររបស់ស្មរបន្ទាល់ព្រះយេហូវ៉ានៅសម័យថ្មីៗ បានពោរពេញទៅដោយព្រឹត្តិការណ៍ដែលធ្វើឱ្យរំភើបចិត្តខ្លាំង។ ចាប់តាំងពីឆ្នាំ១៨៧០ កាលដែលមានពួកសិក្សាព្រះគម្ពីរតែមួយក្រុមយ៉ាងតូចនៅរដ្ឋប៉ិនស៊ីវ៉ានីនោះ មកដល់ឆ្នាំ២០០០ ស្មរបន្ទាល់ព្រះយេហូវ៉ាបានលូតលាស់មានជាង៩០.០០០ក្រុមជំនុំទូទាំងពិភពលោក។ ពីដើម គ្រប់ប្រកាសនវត្ថុខាងព្រះគម្ពីរខ្លះរបស់ស្មរបន្ទាល់ព្រះយេហូវ៉ា បានត្រូវបោះពុម្ពនៅក្នុងអាគាររោងចក្រដែលបានជួលពីគេ។ ប៉ុន្តែ តាំងពីឆ្នាំ១៩២៧មក ប្រកាសនវត្ថុជាច្រើនទៅទៀតបានត្រូវបោះពុម្ពឡើងនៅក្នុងអាគាររោងចក្រដែលមាន៨ជាន់ នៅទីក្រុងប្រ៊ុគ្លីនរដ្ឋញូយ៉ក ដែលជារបស់ផងសមាគមប៉មយាមខាងព្រះគម្ពីរនិងខិត្តប័ណ្ណនៃរដ្ឋញូវយ៉កជាសាជីវកម្ម។ ឥឡូវអាគារនេះបានត្រូវពង្រីករហូតដល់អាគាររោងចក្រនិងអាគារការិយាល័យដែលផ្តុំគ្នាជាច្រើនទៀត។ គឺមានអាគារនៅជិតនោះជាច្រើនទៀតនៅទីក្រុងប្រ៊ុគ្លីន ដែលជាទីលំនៅសម្រាប់ពួកធ្វើការដោយស្ម័គ្រចិត្ត ដែលត្រូវការជាចាំបាច់ដើម្បីធ្វើប្រតិបត្តិការរោងចក្របោះពុម្ពព្រមទាំងដីចំការ។ កន្លែងនោះបោះពុម្ពទស្សនាវដ្ដី*ប៉មយាម* ហើយទស្សនាវដ្ដី*ភ្ញាក់រឭក!* ហើយផលិតម្ហូបសម្រាប់អ្នកធ្វើការដែលបំរើនៅកន្លែងមួយៗ។ អ្នកធ្វើការដោយស្ម័គ្រចិត្តម្នាក់ៗទាំងនោះទទួលប្រាក់សំណងមួយចំនួនតូចសម្រាប់សេចក្តីត្រូវការផ្ទាល់ខ្លួន។

# មហាសន្និបាតអន្តរជាតិ

នៅឆ្នាំ១៨៩៣គេបានធ្វើមហាសន្និបាតអន្តរជាតិជាលើកទីមួយនៅក្រុងឆិខាហ្គោ រដ្ឋអ៊ីលីណោយសហរដ្ឋអាមេរិក។ ៣៦០នាក់បានមករួមប្រជុំគ្នានៅទីនោះ ហើយអ្នកថ្មី៧០អ្នកបានធ្វើបុណ្យជ្រមុជទឹក។ ពេលក្រោយបង្អស់ដែលគេធ្វើសន្និបាតអន្តរជាតិយ៉ាងធំសម្បើម ដែលមានតែមួយក្នុងផែនដីទាំងមូលនោះ បានរៀបចំឡើងនៅទីក្រុងញូវយ៉កនៅឆ្នាំ១៩៥៨។ គេបានប្រើកីឡាមណ្ឌលយ៉ាង្គីនិងកីឡាមណ្ឌលប៉ូឡូដែលនៅមាននៅឡើយនៅពេលនោះ។ កម្រិតចំនួនមនុស្សដែលផ្តុំគ្នានៅទីនោះគឺ២៥៣.៩២២នាក់ ហើយអ្នកថ្មីដែលធ្វើបុណ្យជ្រមុជទឹកនោះមានចំនួន៧.១៣៦នាក់។ តាំងពីពេលនោះមក មហាសន្និបាតអន្តរជាតិបានមានតៗគ្នាក្នុងប្រទេសជាច្រើន។ បើសរុបទៅ សន្និបាតអន្តរជាតិដែលមានតៗគ្នានោះមានជាងមួយពាន់នៅទូទាំងផែនដីនេះ។





Copyright © 2004 Watchtower Bible and Tract Society of Pennsylvania. All rights reserved.